សុន្ទរកថារបស់ **ឯកឧត្តម លោក ម៉ាសាហ៊្វូមី គូរ៉ូគី**

ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព របស់ប្រទេសជប៉ុនប្រចាំកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ

សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ របស់ប្រទេសជប៉ុន

១២ តុលា ២០១២

**សូមគោរព លោកវេជ្ជបណ្ឌិត គីមស្នួរ ភិរុណ ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ចាម!**
**សូមគោរព លោកវេជ្ជបណ្ឌិត មាស ជា ប្រធានមន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមាន សេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយមន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម។ ជំនួយដែលមានថវិកាសរុបចំនួន ១២៣,៣០៤ដុល្លារអាមេរិក គឺផ្តល់ជូនសម្រាប់គម្រោងសាងសង់អគារបណ្តុះបណ្តាលនៅក្នុងមន្ទីរពេទ្យដែលរួមមានសាលឧទ្ទេស បន្ទប់ហ្វឹកហាត់ កន្លែងស្នាក់នៅ និងបន្ទប់ធនធាន។

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកការអភិវឌ្ឍវិស័យសុខាភិបាលជាវិស័យអាទិភាពមួយ ហើយបាននិងកំពុងបន្តដោះស្រាយបញ្ហាសុខភាពដែលកំពុងប្រឈម។ ដោយអនុលោមតាមគោលការណ៍នេះ រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តឧបត្ថម្ភគាំទ្រដល់វិស័យសុខាភិបាលនៅកម្ពុជាតាមរយៈការសាងសង់អគារមន្ទីរពេទ្យ ការផ្តល់សម្ភារៈបរិក្ខារពេទ្យ និងការអភិវឌ្ឍធនធានមនុស្ស។

រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជំនួយប្រមាណ១២លានដុល្លាអាមេរិកដល់មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាមសម្រាប់ការសាងសង់អគារសល្យសាស្ត្រ និងសម្ភព រោគស្ត្រី អគារវះកាត់ សាលប្រតិបត្តិការវះកាត់ ផ្នែកសង្គ្រោះបន្ទាន់និងថតឆ្លុះ ដោយមានបំពាក់សម្ភារៈបរិក្ខារពេទ្យដែលចាំបាច់ ដែលគម្រោងនោះត្រូវបានបើកពិធីសម្ពោធក្រោមអធិបតីភាពរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាកាលពីខែមករាឆ្នាំ២០១១។

គម្រោងថ្មីដែលចុះហត្ថលេខានៅថ្ងៃនេះនឹងផ្តល់អត្ថប្រយោជន៍ដល់បុគ្គលិកសុខាភិបាល និងសិស្ស -និសិត្សដែលមកពីខេត្តកំពង់ចាម កំពង់ធំ ព្រៃវែង និងស្វាយរៀងដើម្បីចូលរួមក្នុងវគ្គបណ្តុះបណ្តាលនៅមន្ទីរពេទ្យប្រមាណ១,០០០នាក់។ ការសាងសង់អគារបណ្តុះបណ្តាលនៅក្នុងមន្ទីរពេទ្យនឹងធ្វើឲ្យបុគ្គលិកមន្ទីរពេទ្យអាចទទួលបានការបណ្តុះបណ្តាល និងបន្តផ្តល់សេវាសុខាភិបាលជូនអ្នកជំងឺក្នុងពេលដំណាលគ្នា។ អគារបណ្តុះបណ្តាលនេះក៏នឹងផ្តល់វគ្គបណ្តុះបណ្តាលផ្នែកឆ្មបដែលជាកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេសរបស់ជប៉ុន។

ខ្ញុំជឿជាក់ថាអគារបណ្តុះបណ្តាលថ្មីនេះ និងជំនួយដទៃទៀតដែលបានផ្តល់ដោយរដ្ឋាភិបាលជប៉ុនជូនដល់មន្ទីរពេទ្យនឹងរួមចំណែកក្នុងការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកសុខាភិបាល និងគុណភាពនៃសេវាសុខាភិបាលក្នុងមន្ទីរពេទ្យ។ ខ្ញុំសង្ឃឹមថាមន្ទីរពេទ្យបង្អែកខេត្តកំពង់ចាមនៅតែបន្តដើរតួនាទីសំខាន់ក្នុងការផ្តល់សេវាថែទាំសុខភាពដល់ប្រជាជននៅប៉ែកបូព៌ានៃប្រទេសកម្ពុជា។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។ សូមអរគុណ!